# សុន្ទរកថារបស់**ឯកឧត្តមម៉ាសាហ្វ៊ូមី គូរ៉ូគី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

០៤ តុលា ២០១២

**សូមគោរព លោក ជា ជាតិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ!**
**សូមគោរព អស់លោក លោកស្រី!**
**ប្អូនៗសិស្សានុសិស្សទាំងអស់!**

ខ្ញុំមា នសេចក្តីសោមនស្សរីករាយ ដើម្បី ចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ។ ជំនួយជាថវិកាសរុប៩៨,៨៨០ដុល្លាអាមេរិកគឺផ្តល់ជូនសម្រាប់គម្រោងសាងសង់អគារសិក្សាថ្មីមួយខ្នងមាន៧បន្ទប់ និងបរិក្ខារអនាម័យ នៅអនុវិទ្យាល័យគោកបញ្ញាន់។

យើងបានកត់សម្គាល់ឃើញថា សិស្សានុសិស្សមួយចំនួននៃអនុវិទ្យាល័យគោកបញ្ញាន់កំពុងប្រើប្រាស់បន្ទប់សិក្សារបស់សាលាបឋមសិក្សាដែលនៅក្បែរនោះ ហើយយើងត្រូវការបន្ថែមបន្ទប់សិក្សាជាបន្ទាន់នៅអនុវិទ្យាល័យដោយសារការកើនឡើងនៃចំនួនសិស្សនៅបឋមសិក្សា។

តាមរយៈគម្រោងនេះ សិស្សានុសិស្សប្រមាណ៦០០នាក់នឹងអាចសិក្សានៅក្នុងបន្ទប់សិក្សារបស់ពួកគេផ្ទាល់ ហើយជាមួយគ្នានេះ សិស្សនៅសាលាបឋមសិក្សានឹងអាចប្រើប្រាស់បន្ទប់សិក្សារបស់ពួកគេយ៉ាងពេញលេញ។ ជាងនេះទៅទៀត គម្រោងនេះនឹងលើកទឹកចិត្តសិស្សបឋមសិក្សាក្នុងតំបន់ឲ្យបន្តការសិក្សានៅកម្រិតអនុវិទ្យាល័យ។

ការអប់រំ និងអភិវឌ្ឍន៍ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេសនាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ការអប់រំ និងការអភិវឌ្ឍន៍ធនធានមនុស្សដោយចាត់ទុកជាមុំមួយនៃបណ្តាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណសម្រាប់អភិវឌ្ឍន៍ជាតិរបស់ខ្លួន។ ដោយអនុលោមតាមគោលការណ៍នេះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តពង្រីកការផ្តល់ជំនួយឧបត្ថម្ភដល់វិស័យអប់រំ និងការអភិវឌ្ឍន៍ធនធានមនុស្សនៅប្រទេសកម្ពុជា។

ខ្ញុំសង្ឃឹមថាសិស្សានុសិស្សនៅអនុវិទ្យាល័យគោលបញ្ញាន់នឹងខិតខំរៀនសូត្រក្នុងបន្ទប់សិក្សាថ្មីព្រមទាំងជួយថែរក្សាឲ្យបានស្អាតសម្រាប់ពួកគេផ្ទាល់ ក៏ដូចជាសម្រាប់សិស្សានុសិស្សដែលនឹងត្រូវសិក្សានាពេលអនាគត។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!